N° 1 ) Janvier 1952 )
Reçu le 12-3
« Kampuchéak soriya »
INDOCHINE FRANÇAISE
RÉGIE DU DÉPÔT LÉGAL

# កម្ពុជសុរិយា

ទស្សនាវដ្ដី ផ្សាយដំណឹងខាងសាសនា និងអក្សរសាស្ត្រ

ពុទ្ធសាសនបណ្ឌិត្យ
INSTITUT BOUDDHIQUE

ឆ្នាំទី ២៤ ខែមករា លេខ ១

ព.ស. ២៤៩៤ – គ.ស. ១៩៥២

# កម្ពុជសុរិយា

ទស្សនាវដ្ដី ផ្សាយដំណឹងខាងសាសនា និងអក្សរសាស្ត្រ
បោះពុម្ពផ្សាយអំពីពុទ្ធសាសនបណ្ឌិត្យ


| ផ្នែកសាសនា | បញ្ជីរឿង | ទំព័រ |
| --- | --- | --- |
| សាភណ័យធម្មកថា ............. | ព្រះមហា កែ អៀន ....... | ៣ |
| ពន្លឺអាស៊ីទ្វីប (តមក) ........... | លោកភ័យ - ប៉ុក ......... | ១១ |
| ពុទ្ធសាសនាធិប្បាយ ............. | ព្រះបាឡាត់ ទូ ឌម ....... | ១៦ |
| **ផ្នែកអក្សរសាស្ត្រ** | | |
| ការប្រើអក្សរខ្មែរ ............... | ណាយ តិត - ពិន ......... | ២៤ |
| រឿងគ្រូសាញ់អ្នកខ្លាំងពូកែ .......... | សាស្ត្រាចារ្យ ផេង - ជ្រីវ ..... | ៣១ |
| ការបណ្ដុះនិស្ស័យ (តមក)........ | ព្រះមហាឧត្តមវិជ្ជា ប៉ុង - ប៉ម ... | ៣៩ |
| រឿងសាមកុក (តមក)............ | ខកញ៉ា ទូ - កន ......... | ៤៧ |
| រឿងអារក្សថ្លែងរឿងម្ភៃប្រាំ (តមក).... | លោកសាង - សាវ៉ាត....... | ៥៦ |
| **កំណត់ទីន៍ប្រវត្តិការណ៍** | | |
| ពិធីបុណ្យដ៏ឧឡារិកនៅវត្តដើមអំពិល ខេត្រ ប៉ោលាវ (យៀកណាម)......... | ព្រះមហា ឈិត - កំលិន .... | ៦៩ |
| ឧត្តមគតិនៃពុទ្ធបរិស័ទវត្តលង្កា........ | សមាគមមិត្តសាលាបាលី .... | ៧៩ |



មួយឆ្នាំមាន ១២ សៀវភៅ — ដំឡៃជាវ ១៨៣រ.០០

# សារាណីយធម្មកថា

## ព្រះមហា កែ - អឿន (វីរិយបញ្ញោ)

វត្តព្រះព្រហ្មរតន៍ ខេត្តសៀមរាប រៀបរៀង

## ឃុនសុវត្ថិវេទី យូរ - អ៊ុន អ្នកពិនិត្យកែ

............

## នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស ។

សូមនមស្សការចំពោះព្រះភគវន្តមុនីអរហំសម្មាសម្ពុទ្ធ ព្រះអង្គនោះ (ព្រមទាំងព្រះធម៌ និងព្រះអរិយសង្ឃ ដោយសេចក្តីគោរព) ។

វេលានេះ ខ្ញុំព្រះករុណា អាត្មាភាព នឹងសូមដកស្រង់យកសារាណីយធម៌ ដែលព្រះសម្មាសម្ពុទ្ធជាបរមគ្រូ ទ្រង់សំដែងទុកក្នុងគម្ពីរអង្គុត្តរនិកាយឆក្កនិបាត មកអធិប្បាយជាផ្លូវលោកខ្លះ ផ្លូវធម៌ខ្លះ តាមសមគួរ ដូចតទៅនេះ:

មនុស្សគ្រប់ជាតិគ្រប់ភាសា ដែលកើតមកក្នុងពិភពលោកនេះ សុទ្ធតែមានកិច្ចការ គួរប្រកបគួរប្រស្រ័យគ្នាទៅវិញទៅមក ដែលជាផ្លូវធម៌សាសនា ឬ ក៏ផ្លូវលោក ។

ក្នុងក្រុម ឬ សង្គមនីមួយៗ ត្រូវការស្រ័យប្រស្រ័យការទាក់ទងចងភ្ជាប់គ្នាជាកំឡាំង, បើមិនមានកំឡាំងការចងភ្ជាប់គ្នាទេ, ពុំអាចនឹងប្រកបកិច្ចការប្រស្រ័យគ្នាបានឡើយ ។ កំឡាំងការចងភ្ជាប់គ្នានេះជាធម្មជាតិ

សំខាន់បំផុតក្នុងកិច្ចការគ្រប់យ៉ាង ព្រោះហេតុនោះ បុគ្គលគួររក្សាការចងបាច់គ្នាជាកម្លាំងឲ្យរឹងប៉ឹង សម្រាប់ប្រកបកិច្ចការតាមក្រុមសង្គមរបស់ខ្លួន ៗ ក្រុមសង្គមនីមួយៗ ដែលមិនបានសេចក្ដីសុខសេចក្ដីចម្រើនអស់កាលយូរអង្វែងទៅបានមិនបែកចិត្តគំនិតគ្នា មិនច្រណែនឈ្នានិះគ្នា មិនប្រឆាំងប្រជែងប្រណាំងគ្នាជាដើម ក៏ដោយអាស្រ័យសារាណីយធម៌ ៗ

សារាណីយធម៌នោះ ប្រែថា "ធម៌ជាទីតាំងនៃសេចក្ដីរឭកដល់គ្នានិងគ្នាទៅវិញទៅមក" មាន ៦ យ៉ាង គឺ:

១— មេត្តាកាយកម្ម - អំពើកាយប្រកបដោយមេត្តា

២— មេត្តាវចីកម្ម - អំពើវាចាប្រកបដោយមេត្តា

៣— មេត្តាមនោកម្ម - អំពើចិត្តប្រកបដោយមេត្តា

៤— លាភ: - ការចែករំលែកលាភដល់គ្នីគ្នា

៥— សីល: - ការរក្សាសីលចរិយាឲ្យមានសណ្ដាប់ធ្នាប់ល្អ

៦— ទិដ្ឋិ - ការធ្វើសេចក្ដីឃើញឲ្យត្រឹមត្រូវ ៗ

សារាណីយធម៌នេះ ព្រះភគវន្តមុនីទ្រង់សំដែងថា "ម្នាលភិក្ខុទាំងឡាយ! ធម៌ទាំង ៦ យ៉ាងនេះ តែងធ្វើអ្នកប្រតិបត្តិឲ្យជាទីស្រឡាញ់ជាទីគោរពរាប់អានរបស់អ្នកដទៃ នាំឲ្យមានសេចក្ដីសង្គ្រោះដល់គ្នានឹង

គ្នា នាំឲ្យមានសេចក្ដីមិនទាស់ទែងខ្វែងគំនិតគ្នា នាំឲ្យមានសេចក្ដីព្រមព្រៀងគ្នាជាពួកមួយ " ។

លំដាប់តពីនេះ នឹងដកស្រង់យកបទមាតិកាមួយៗ មកអធិប្បាយតាមលំដាប់រៀងទៅ ដូចតទៅនេះ :-

មេត្តាកាយកម្ម·— ភិក្ខុសាមណេរមានចិត្តមេត្តាជួយខ្វល់ខ្វាយធ្វើកិច្ចការដែលគួរធ្វើដល់គ្នានឹងគ្នា គឺភិក្ខុសាមណេរជាអន្តេវាសិក សទ្ធិ-វិហារិកត្រូវធ្វើកិច្ចវត្តប្រតិបត្តិដល់ឧបជ្ឈាយ៍អាចារ្យ មានការប្រគេនទឹកក្ដៅត្រជាក់ទឹកឈើស្ទន់ជាដើម ។ កាលបើអន្តេវាសិកឬសទ្ធិវិហារិកមានរោគាពាធ ត្រូវតែឧបជ្ឈាយ៍អាចារ្យ ជួយព្យាបាលរក្សា មានដាក់ថ្នាំថែទាំផ្សំជាដើម ។ បើមិនបានធ្វើដូច្នោះទេ ត្រាន់តែមកត្រួតត្រាមើលឲ្យឃើញថាជាការតើពើដោយកាយ ។ ពុំនោះសោត ភិក្ខុសាម-ណេរទាំងឡាយឯណា កាលបើភិក្ខុសាមណេរផងគ្នាមានកិច្ចអ្វីដែលត្រូវធ្វើដោយកាយមានកាត់ - ដេរចីវរជាដើម ភិក្ខុសាមណេរនោះៗ មកជាគ្នាជួយធ្វើកិច្ចការទាំងនោះ ឬកិច្ចណាមួយដែលជាកិច្ចត្រូវអាស្រ័យនឹងបុរសបុគ្គលច្រើនគ្នាទើបប្រព្រឹត្តទៅបាន ដូចជាខ្វល់ខ្វាយរកថ្នាំធ្វើថ្នាំរក្សាបព្វជិតដែលទុព្វលភាពដោយអាពាធមានគ្រុនពិសជាដើម ខាងក្រៅមានសត្វអាសិរពិសចឹកជាដើម ។

មេត្តាវចីកម្ម·— ភិក្ខុសាមណេរមានចិត្តមេត្តាជួយណែនាំប្រៀនប្រដៅធម៌វិន័យ ជួយដាស់តឿនក្រើនរំលឹកចង្អុលបង្ហាញទោស គុណ

ផ្លូវដែលខុស ឲ្យលះបង់អំពើទុច្ចរិត បង្អុលហេតុផលក្នុងផ្លូវដែលល្អប្រពៃ ដែលប្រកបដោយធម៌វិន័យឲ្យមានដំណើរដើរទៅក្នុងផ្លូវល្អ ។

ម្យ៉ាងទៀត ភិក្ខុសាមណេរមានមេត្តាពោលប្រស្រ័យគ្នាដោយផ្លូវ បដិសណ្ឋារៈ សួរសេចក្ដីសុខទុក្ខដល់គ្នានឹងគ្នាតាមសមគួរ ឬភិក្ខុសាមណេរមានមេត្តាប្រាប់វិធីរៀនវិជ្ជាខាងដើមតាំងពីសរសេរ មើលទន្ទេញ បង្ហាញគន្ថធុរៈ វិបស្សនាធុរៈ ឲ្យទានុសាសន៍ ។

មេត្តាមនោកម្ម — ភិក្ខុសាមណេរមានចិត្តមេត្តាប្រាថ្នាប៉ុនប៉ងមិនចងពៀរដល់គ្នានឹងគ្នា មិនបៀតបៀនដល់គ្នានឹងគ្នា ប្រាថ្នាសេចក្ដីសុខ សេចក្ដីចម្រើនដល់គ្នានឹងគ្នាដោយចិត្តស្មោះត្រង់ ។

លាភៈ — ភិក្ខុសាមណេរណាបានវត្ថុណាមួយ គឺចីវរ, បិណ្ឌបាត, ទីដេក ទីអង្គុយឬថ្នាំកែរោគ ជារបស់ប្រកបដោយធម៌ បានមកដោយធម៌ កើតឡើងដោយធម៌ គួរភិក្ខុសាមណេរនោះចែករំលែកលាភនោះៗ ដល់គ្នានឹងគ្នា ឲ្យបរិភោគប្រើប្រាស់តាមដែលបានមកតិចច្រើន ។ ឧបជ្ឈាយ៍អាចារ្យក៏ដោយ កាលបើលាភសក្ការៈ កើតមានបានមកដោយធម៌ក៏ត្រូវចែករំលែកដល់សទ្ធិវិហារិក អន្តេវាសិក បរិភោគប្រើប្រាស់តាមវត្ថុដែលមានបាន ។

សីលៈ — ភិក្ខុសាមណេរត្រូវប្រព្រឹត្តខ្លួនឲ្យស្មើនឹងពួកសព្រហ្មចារីទាំងឡាយដោយសីល គឺមិនត្រូវធ្វើសីលរបស់ខ្លួនឲ្យពព្រុសពពាល

សៅហ្មង ដែលជាទីរង្កៀសមិនទុកចិត្ត ដល់ពួកសព្រហ្មចារីទាំងឡាយ ត្រូវធ្វើខ្លួនឲ្យជាអ្នកបរិសុទ្ធស្អាត ប្រាសចាកសេចក្ដីវិបត្តិនៃសីល ។

ទិដ្ឋិ— ភិក្ខុសាមណេរត្រូវប្រព្រឹត្តខ្លួនឲ្យស្មើនឹងពួកសព្រហ្មចារីទាំងឡាយដោយទិដ្ឋិ គឺ សព្រហ្មចារីទាំងឡាយប្រព្រឹត្តកាយវាចាចិត្តយ៉ាងណា ដើម្បីជាដំណើរទៅរកបញ្ញា ដែលជាគ្រឿងឃ្មាតកំចាត់សត្រូវ គឺកិលេសនាំផងអ្នកប្រព្រឹត្តតាមឲ្យដល់នូវសេចក្ដីអស់ទៅ នៃទុក្ខដោយប្រពៃ, ភិក្ខុសាមណេរនោះត្រូវប្រព្រឹត្ត កាយ វាចា ចិត្តឲ្យស្មើនឹងពួកសព្រហ្មចារីទាំងឡាយនោះ ។

ធម៌ទាំង ៦ យ៉ាងនេះ មានអានុភាពនាំឲ្យអ្នកកាន់អាចរលឹកដល់គ្នានឹងគ្នា ធ្វើមនុស្សឲ្យស្រឡាញ់គ្នា នាំឲ្យមានសង្គ្រោះគ្នា មិនឲ្យទាស់ទែងគ្នា ឲ្យមានសេចក្ដីព្រមព្រៀងគ្នាជាពួកមួយ ៗ ព្រោះធម្មតាការរលឹកក្ដី ការស្រឡាញ់គោរពក្ដី តែងកើតមានព្រោះអាស្រ័យឧបការគុណដែលខ្លួនបានធ្វើទុកដល់គេម្យ៉ាង, ព្រោះអាស្រ័យកាយវាចាចិត្តម្យ៉ាង ៗ កាលបើភិក្ខុសាមណេរ បានធ្វើសេចក្ដីខ្វល់ខ្វាយក្នុងកិច្ចធុរៈរបស់ពួកសព្រហ្មចារីដោយកាយវាចាប្ដុំដោយមេត្តាចិត្ត គិតនឹងជួយមែនៗ មិនចង់បានផលប្រយោជន៍ផ្ទាល់ខ្លួន ក្នុងទីចំពោះមុខយ៉ាងណា ក្នុងទីកំបាំងមុខក៏យ៉ាងនោះដែរ, ពួកសព្រហ្មចារីបានទទួលឧបការរបស់លោកហើយ តែងមានចិត្តគិតនឹងតបស្នងសងខ្វះ ក្នុងវេលាដែលគួរ ៗ មិនត្រឹមតែ

ប៉ុណ្ណោះសោតទេ សូម្បីមិនបានជួយខ្វល់ខ្វាយក្នុងកិច្ចធុរៈដោយកាយ ពចា តែចិត្តប៉ុនប៉ងប្រាថ្នាសេចក្ដីសុខប្រយោជន៍ដល់គ្នានឹងគ្នាហើយ, អាការកាយពចា ដែលសំដែងឲ្យប្រាកដចេញមកខាងក្រៅនោះ ក៏គង់មិនជាទុក្ខដល់ក្នុងនៃពួកសព្រហ្មចារីនោះ, បានមេត្រីចិត្តដូច្នេះហើយ ក៏រមែងសំដែងមេត្រីចិត្តតបស្នងវិញខ្លះមិនខាន ៗ

មួយទៀត ភិក្ខុសាមណេរបានលាភមកដោយធម៌ហើយមិនទុកដាក់លាភប៉ុណ្ណោះប្រើប្រាស់តែម្នាក់ឯង តែងចែករំលែកដល់ពួកសព្រហ្មចារីផងគ្នា, កាលបើពួកសព្រហ្មចារីបានទទួលវត្ថុអំពីលោកណា លុះគេបានលាភមកដោយធម៌ ក៏នឹងចែករំលែកតបលោកវិញមិនខាន ៗ បើទុកជាមិនធ្វើឧបការគុណក៏ដោយចុះ ប្រសិនជាភិក្ខុសាមណេរ គ្រាន់តែប្រព្រឹត្តខ្លួនឲ្យជាអ្នកមានសីលបរិសុទ្ធ ឲ្យជាអ្នកមានទិដ្ឋិ សេចក្ដីយល់ឃើញប្រពៃហើយ ពួកសព្រហ្មចារីទាំងឡាយ ក៏នឹងជ្រះថ្លាចំពោះគុណ គឺសេចក្ដីត្រេកអររបស់លោកមិនខាន ៗ ភិក្ខុសាមណេរដែលប្រព្រឹត្តដូច្នេះ រមែងជាទីរឭកជាទីស្រឡាញ់គោរពរាប់អាន របស់ពួកសព្រហ្មចារីដទៃៗ នាំគ្នាគិតសង្គ្រោះគ្នានឹងគ្នា ៗ មនុស្សដែលវិវាទទាស់ទែងគ្នា ក៏ព្រោះមិនមានបំណងឲ្យជាប្រយោជន៍ដល់គ្នានឹងគ្នាខ្លះ ព្រោះមិនមានធ្វើឧបការ-គុណដល់គ្នានឹងគ្នាខ្លះ ៗ ចំណែកបុគ្គលដែលមានសេចក្ដីសាមគ្គីព្រមព្រៀងគ្នា ក៏ព្រោះអាស្រ័យការសង្គ្រោះគ្នាខ្លះ ព្រោះការលៃលកធួន

ស្រាលគ្នាខ្លះ ៗ កាលបើភិក្ខុសាមណេរតាំងនៅក្នុងគុណធម៌ទាំង ៦ ប្រការនេះហើយ គាបទាញចិត្តពួកសព្រហ្មចារីមិនឲ្យរាំងទាស់ទែងគ្នា ធ្វើឲ្យមានសាមគ្គីជាមួយគ្នា ធ្វើឲ្យជាទីស្រឡាញ់គ្នា នាំឲ្យមានសេចក្ដីសង្គ្រោះគ្នា មិនឲ្យទាស់ទែងខ្វែងគំនិតគ្នា ឲ្យមានសេចក្ដីព្រមព្រៀងគ្នា ។

ធម្មតាបុគ្គលដែលគ្មានមិត្ត កាលបើកិច្ចធុរៈកើតឡើងម្ដង ៗ ត្រូវតែខ្វល់ខ្វាយខ្នះខ្នែងកខ្វេសខ្វាសដោយកម្លាំងខ្លួនម្នាក់ឯង មិនមានបុគ្គលដទៃជួយផង ៗ រូបកាយមានដៃជើងសម្រាប់ជួយ បើខ្វះដៃឬជើងរមែងមានសេចក្ដីលំបាក: ដើមឈើមានឫសនឹងមែកសម្រាប់ជួយឲ្យរស់នៅបាន បើរុក្ខាវយវៈទាំងនោះគ្មានទេ ដើមឈើនោះក៏រស់នៅមិនបាន, ត្រូវខ្យល់បក់មករលំបានដោយងាយ ៗ ធម្មតាមនុស្សទាំងពួងបើរួបរួមគ្នាច្រើន ក៏រមែងមានកម្លាំងច្រើន ។ អម្បោះមួយសរសៃមិនសូវជាប់ប៉ុន្មានទេ ទាញតែមួយប្រិបក៏ដាច់ បើវេញចូលជាធ្នុងមួយ ទើបទាញមិនដាច់ បើទុកជាគោទាញក៏មិនដាច់ ។ ស្រមោចមួយទាំងនឹងទៅជាអ្វី? មនុស្សយើងក៏ដូចគ្នាដែរ ចំពោះខ្លួនមួយនឹងតស៊ូអ្នកណាក៏មិនឈ្នះ ធ្វើអ្វីក៏មិនបានច្រើនដែរ, លុះតែជួយគ្នាទើបបានកម្លាំងច្រើនឡើង, ដោយហេតុទៅ សូម្បីនៅក្នុងទីណា ហើយក្រឡេកមើលជុំវិញមិនស្គាល់អ្នកណាម្នាក់សោះ ក៏រមែងមិនបានសុខ ។ ព្រោះហេតុដូច្នេះសេចក្ដីមេត្រីស្និទ្ធស្នាលគ្នាល្អ ទើបជាផលដែលបុគ្គលត្រូវស្វែងរកយ៉ាងក្រៃលែង

សមដូចពុទ្ធភាសិតថា វិស្សាសា បរមា ញាតិ "សេចក្ដីស្និទ្ធស្នាល មេត្រីរាប់អានគ្នា ជាញាតិយ៉ាងក្រៃលែង" ។ ឯសេចក្ដីមេត្រីនោះ តែងកើតឡើងដោយសារាណីយធម៌ទាំង៦ យ៉ាង ដូចសំដែងមកនេះ ។ ធម្មតាបុគ្គលដែលជាទីស្រឡាញ់គោរពរាប់អានរបស់ប្រជុំជន ក៏ព្រោះអាស្រ័យឧបការគុណដែលខ្លួនបានធ្វើទុកដល់គេ ។ បើបុគ្គលបានធ្វើសេចក្ដីខ្នះខ្នែងខ្វល់ខ្វាយក្នុងកិច្ចធុរៈរបស់គ្នានឹងគ្នា ដោយកាយវាចាក្ដី ដោយមេត្តាចិត្តគិតនឹងជួយពិតៗក្ដី មិនមានបំណងផលប្រយោជន៍ ក្នុងទីចំពោះមុខយ៉ាងណា ក្នុងទីកំបាំងមុខក៏យ៉ាងនោះដែរ អ្នកដែលបានទទួលឧបការដូច្នោះ ក៏នឹងមានចិត្តសោមនស្សស្មោះសរចំពោះឧបការគុណ គិតនឹងតបស្នងឧបការខ្លះក្នុងវេលាដែលគួរ ។ អ្នកដែលទទួលមេត្រីចិត្តដូច្នេះ ខាងក្រោយក៏នឹងសំដែងមេត្រីចិត្តតបវិញ ។

ម្យ៉ាងទៀត កាលបើបានទ្រព្យសម្បត្តិដោយផ្លូវល្អ ហើយមិនលាក់លៀមទុកបរិភោគប្រើប្រាស់តែម្នាក់ឯង អាចចែករំលែកដល់បុគ្គលដែលគួរឲ្យតាមមានតាមបាន, អ្នកដែលទទួលសេចក្ដីសង្គ្រោះដូច្នោះ ក៏នឹងមានចិត្តសោមនស្សស្រឡាញ់ បើបានទ្រព្យអ្វីៗ ក៏នឹងរំលែកចែកមកវិញ ។ សមដូចភាសិតថា បូជកោ លភតេ បូជំ "អ្នកបូជាគេរមែងបានគេបូជាវិញ" វន្ទកោ បដិវន្ទនំ "អ្នកសំពះគេ រមែងបានគេសំពះវិញ" ភាសិតខ្មែរថា "ថោកអ្វីនឹងដៃ ថ្លៃអ្វីនឹងមាត់" ។

(មានត)

## សារាណីយធម្មកថា

## ព្រះមហា កែ-អឿន (វិរិយបញ្ញោ)

*វត្តព្រះព្រហ្មរតន៍ ខេត្រសៀមរាប រៀបរៀង*

ឃុនសុវត្ថិផទី ឃួរ-អ៊ុន អ្នកពិនិត្យកែ

(តចប់)

---

ន័យ ១ ទៀត បុគ្គលប្រព្រឹត្តខ្លួនឲ្យមានកាយវាចារៀបរយល្អ បើនឹងទៅក្តី ក៏មិនឲ្យអ្នកដទៃលំបាកដោយឥតហេតុ បើនឹងពោលក្តីពោលតែវាចាពីរោះ គួរទុកក្នុងចិត្ត, តែងមានសេចក្តីឃើញត្រូវតាមហេតុតាមផល, កាលបើគិតក្តី ក៏សុទ្ធតែជាហេតុឲ្យសម្រេចផលល្អ ជាប្រយោជន៍ដល់ខ្លួននឹងអ្នកដទៃ, អ្នកដែលប្រព្រឹត្តដូច្នេះ អាស្រ័យគុណគឺសេចក្តីល្អរបស់ខ្លួន តែងជាទីរីករាយនៃប្រជុំជន នាំគ្នាសង្គ្រោះចិត្តគ្នានឹងគ្នា ៗ ព្រោះហេតុដូច្នោះហើយ អ្នកមានបំណងចង់បានសេចក្តីសុខដល់ពួកក្រុម សង្គម គណៈ ប៉ងនឹងចងមេត្រីនឹងអ្នកដទៃ មិនប្រាថ្នាចំពោះប្រយោជន៍ខ្លួនតែម្យ៉ាង គប្បីបំពេញសារាណីយធម៌ ៦ យ៉ាងនេះ ឲ្យបរិបូណ៌ក្នុងសន្តានដូចអធិប្បាយមកនេះ ៗ

បន្ទាប់អំពីនេះ នឹងសំដែងបំភ្លឺដល់គ្រហស្ថជាសេចក្តីល្មមសមគួរ ៗ ធម៌ទាំង ៦ យ៉ាងនេះ គ្រហស្ថក៏ត្រូវប្រព្រឹត្តប្រតិបត្តិបានដូចគ្នា ៗ ឯកិច្ចការខាងគ្រហស្ថនេះ មានក្រុម ឬ គណៈសង្គមច្រើនជាអនេកប្បការ

ណាស់ កប់ចាប់តាំងអំពីព្រះរាជាជាម្ចាស់ផែនដីនិងអ្នករាជការជាលំដាប់ៗ ក្នុងព្រះរាជអាណាចក្រទាំងមូល រហូតទៅដល់ប្រជារាស្ត្រទាំងអស់ សុទ្ធតែមានក្រុម សង្គម គណៈគ្រប់ៗមុខមាត់ ។ ក្នុងក្រុម សង្គម គណៈនីមួយៗ សុទ្ធតែមានមេបញ្ជាការ ជានាយកលើក្រុមសង្គមគណៈនោះៗ មានការត្រួតត្រាបញ្ជាការទៅលើអ្នកនៅក្រោមបង្គាប់របស់ខ្លួនៗ, លោកជានាយកទាំងនោះ ដែលជាអ្នកបញ្ជាការត្រួតត្រាលើគេ ត្រូវជាអ្នកប្រកបដោយធម៌ជាគុណសម្បត្តិ សម្រាប់ខ្លួន ៦ ប្រការគឺ :–

១ — ទម – ជាអ្នកមានសេចក្ដីអត់ធន់ ចំពោះអនិដ្ឋារម្មណ៍គឺ អារម្មណ៍ដែលនាំឲ្យកំហឹងកើតឡើងផ្សេងៗ ។

២ — ជាគរិយៈ – ជាអ្នកមានសេចក្ដីភ្ញាក់រលឹករឿយៗ ចំពោះ ករណីយកិច្ចគ្រប់យ៉ាង ។

៣ — ឧដ្ឋានៈ – ជាអ្នកមានសេចក្ដីឧស្សាហ៍ព្យាយាម ក្នុង ករណីយកិច្ចដែលត្រូវធ្វើ មិនរួញរា ។

៤ — សំវិភាគៈ – មានការចែករំលែកលាភដែលបានមក ដល់អ្នកដែលនៅក្រោមបង្គាប់ ជាសាធារណ៍ តាមមានបាន ។

៥ — ទយា – ជាអ្នកមានសេចក្ដីអាណិតអាសូរទូទៅ ដល់អ្នកនៅក្រោមបញ្ជាការ ។

៦. តិក្ខតា – មានការពិនិត្យត្រួតត្រា ពិចារណាមើលហេតុផ្សេងៗ ដោយម៉ត់ចត់ ។

បុគ្គលជានាយកលើគេ បើប្រកបដោយធម៌ជាគុណសម្បត្តិ ទាំង ៦ យ៉ាងនេះហើយទើបមានសមត្ថភាពស័ក្តិសមជានាយកបាន ។

បុគ្គលដែលនៅក្រោមបង្គាប់បញ្ជាការ របស់នាយកនោះៗ ត្រូវស្តាប់បង្គាប់គោរពកោតខ្លាចលោកជានាយករបស់ខ្លួន មិនត្រូវតែហើនកោងកាចតាមអំណាចចិត្តអន្ធពាលឡើយ ។

មួយទៀតបុគ្គលជាគ្រហស្ថតាមតែក្រុម សង្គម គណៈណាក៏ដោយ ដែលនឹងនៅដោយសេចក្តីព្រមព្រៀងគ្នា ជាទីស្រឡាញ់គោរពរាប់អានគ្នា បានសេចក្តីសុខ សេចក្តីចម្រើនអស់កាលជាយូរអង្វែងទៅបាន ក៏ដោយអាស្រ័យសារាណីយធម៌ទាំង ៦ ប្រការដែរ ។ ដូច្នេះនឹងលើកយកសារាណីយធម៌នោះមកអធិប្បាយតាមសមគួរតទៅទៀតគឺ :

១. អំពើកាយប្រកបដោយមេត្តា — នោះបានដល់ការខ្នះខ្នែងខ្វល់ខ្វាយជួយគ្នា ដូចជាពួកក្រុមមនុស្សណាមួយ មានកិច្ចធុរៈ កើតឡើងដែលជាកិច្ចត្រូវធ្វើដោយកាយ ពួកមនុស្សដែលនៅក្នុងក្រុមនោះក៏ជួយខ្នះខ្នែងខ្វល់ខ្វាយធ្វើកិច្ចនោះ ឲ្យសម្រេចទៅតាមកំឡាំងរៀងខ្លួន ដូចជាជួបប្រទះមនុស្សឈឺគ្រុនយ៉ាងធ្ងន់ យើងមានសេចក្តីករុណាបន្តក់ថ្នាំ ជួយឈឺឆ្អាលរកគ្រូពេទ្យមករក្សាថែទាំមើលជម្ងឺ, ឬមានភ្លើងឆេះផ្ទះ

អ្នកជិតខាងយើងទៅជួយលត់ ជួយជញ្ជូនយកទ្រព្យរបស់គេ ឲ្យផុតអំពីអន្តរាយ, ទូកលិចក្នុងលង់ទឹក យើងហែលទៅជួយឲ្យរួចផុតពីសេចក្តីអន្តរាយ ដោយហោចទៅ សូម្បីគ្រាន់តែឃើញគេឈឺគ្រុនធ្ងន់ យើងទៅសួរទៅមើលតែប៉ុណ្ណោះក៏គង់ឃើញថា យើងមានសេចក្តីអាណិតអាសូរករុណា, កាលបើយើងមានកិច្ចធុរៈ ឬអន្តរាយកើតដូច្នោះវិញ អ្នកជិតខាងគេក៏គង់មកជួយកិច្ចធុរៈយើងវិញដែរ, នេះហើយហៅថាចងមិត្តមេត្រីនឹងគ្នាទៅវិញទៅមក ។

២. អំពើវាចាប្រកបដោយមេត្តា— នោះបានដល់ការជួយនិយាយដាស់តឿនក្រើនរំលឹកអ្នកណាមួយ ដែលធ្វើខុសអំពីបញ្ញត្តិច្បាប់របស់ស្រុក-នគរជាដើម, មានសេចក្តីករុណាជួយហាមប្រាមឃាត់មិនឲ្យធ្វើ ឬក៏ជួយប្រៀនប្រដៅឲ្យប្រព្រឹត្តក្នុងផ្លូវល្អប្រពៃ ឲ្យប្រកបរបស់ដែលមានប្រយោជន៍ដោយមេត្តាចិត្ត ។

ម្យ៉ាងទៀត ការសំដែងមេត្តាដោយវាចានោះ អ្នកប្រាជ្ញលោកសំដែងទុកថា សូម្បីតែនិយាយសាកសួរសុខទុក្ខដល់គ្នានឹងគ្នា ក៏រាប់ថាជាមនុស្សមានចិត្តល្អ ។ ឯវាចាដែលពីរោះទន់ភ្លន់គួរទុកក្នុងចិត្តនេះ ជាវាចាដែលនិយាយងាយស្រួលជាងវាចាគ្រគោះបោះបោក, វាចាគ្រគោះបោះបោកនោះជាវាចាពិបាកនិយាយ ព្រោះត្រូវប្រយ័ត្នក្រែងគេក្រោធខឹងឬមិនពេញចិត្ត ។

ឯវាចាដែលបាទៅរកគេ រមែងទទួលផលជា ២ យ៉ាងគឺ វាចាអាក្រក់ រមែងឲ្យផលអាក្រក់, វាចាពីរោះទន់ភ្លន់រមែងឲ្យផលល្អ អាចឲ្យបានទទួលសេចក្តីរាប់អានទឹងសាមគ្គីអំពីអ្នកស្តាប់ជាដើម ទាំងអាចមានចិត្តអាណិតអាសូរដល់គ្នាផង ។

៣. អំពើចិត្តប្រកបដោយមេត្តា — នោះបានដល់មេត្តាចិត្តប្រាថ្នាមិនចង់ពៀរដល់គ្នានឹងគ្នា សូម្បីមិនបានជួយខ្នះខ្នែងក្នុងកិច្ចធុរៈដោយកាយវាចាទេ តែចិត្តប៉ុណ្ណោះហើយ អាការកាយនឹងវាចាដែលប្រាកដចេញមកខាងក្រៅនោះ ក៏គង់នឹងត្រូវចិត្តអ្នកដទៃ ។ មនុស្សយើងធ្វើឬគិតអាក្រក់ល្អក៏ព្រោះចិត្ត បើចំពោះតែកាយដូចរូបតុក្កតា, ឯចិត្តដូចមនុស្សទាញកាយ នឹងវាចាប្រព្រឹត្តទៅយ៉ាងណា ក៏ប្រព្រឹត្តទៅតាមចិត្តនោះ ។

សូមចាំកុំភ្លេចថា: យើងមេត្តាគេៗមេត្តាយើង, យើងធ្វើឲ្យគេប៉ុណ្ណា គេធ្វើឲ្យយើងប៉ុណ្ណោះវិញ ។ ការសំដែងមេត្តាចិត្តនេះ កុំថាតែមនុស្ស សូម្បីសត្វតិរច្ឆានទាំងឡាយ មានឆ្កែនឹងឆ្មាជាដើម កាលបើមនុស្សស្រឡាញ់ទៅហើយ វាសំដែងអាការរញ៉េករញ៉ក់បក់កន្ទុយមករកយើង, បង្ហាញឲ្យឃើញថាវាមានសេចក្តីស្រឡាញ់យើង ។

៤ — ការចែករំលែកលាភដល់គ្នីគ្នា — នោះគឺកាលបើបានបច្ច័យឬវត្ថុរបស់ណាមួយដោយធម៌ហើយ អាចចែករំលែកលាភនោះឲ្យ

ដល់ពួកក្រុមសង្គម ឬដល់កូនប្រពន្ធនៅក្នុងទីកន្លែង ផ្ទះសំបែងរបស់ខ្លួន ឬដល់ពួកជនដែលនៅជិតខាងបរិភោគប្រើប្រាស់ពោះតិច-ច្រើនតាមមានតាមបាន ។

៥ — រក្សាសីលបរិយាឱ្យមានសណ្ដាប់ធ្នាប់ល្អ — បានដល់ការមិនធ្វើឱ្យជាទីរង្កៀសរបស់អ្នកដទៃពោលគឺការធ្វើ កិរិយាចរិយាសណ្ដាប់ធ្នាប់នៃកាយវាចាចិត្ត ដែលហៅថាសីល ។ សីលនេះអាចនាំអ្នកដទៃសូម្បីផ្សេងជាតិផ្សេងភាសា ដូចខ្មែរ, ភូមា, មន, លាវជាដើម ឱ្យមានសេចក្ដីប្រព្រឹត្តិត្រូវគ្នាជាធ្លុងមួយបាន ព្រោះកាន់ព្រះពុទ្ធសាសនាដូចគ្នា ។ សីលនេះលោកប្រៀបដូចជាអម្បោះ សម្រាប់ក្រងផ្កាឈើ មានពណ៌ផ្សេងគ្នាយកមកបញ្ចូលជាបៀបមួយ អាចក្រឡេកមើលទៅឃើញល្អគួរជាប់ភ្នែកជាប់ចិត្ត ។ បើអ្នកកាន់សាសនាត្រូវគ្នាហើយ តែប្រព្រឹត្តផ្សេងអំពីពួករបស់ខ្លួន, ក៏រមែងជាទីរង្កៀសរបស់អ្នករួមសាសនាជាមួយគ្នា ជាហេតុឱ្យបែកសាមគ្គីគ្នា ។

៦ — ធ្វើសេចក្ដីឃើញឱ្យត្រឹមត្រូវ — បានដល់សេចក្ដីយល់ឃើញត្រូវគ្នា គឺបុគ្គលដែលនឹងគ្រប់គ្រងគ្នា ជាគណៈ សង្គមបានព្រោះអាស្រ័យសេចក្ដីរួមគ្នាទើបគ្រប់គ្រងគ្នាបាន, បើមានសេចក្ដីឃើញម្នាក់ផ្លូវមួយ ឃ្លាងគ្នាមិនស្របមតិគ្នា ពោះបើមានសេចក្ដីប្រព្រឹត្តិល្អក៏ដោយ ក៏គង់សមាគមនឹងគ្នាទៅមិនបានរហូតឡើយ, ព្រោះខ្វះខាតសេចក្ដីយល់

មិនព្រមព្រៀងគ្នា រមែងជាហេតុឲ្យកើតទាស់ទែងខ្វែងគំនិតគ្នា មិនអាចធ្វើករណីយកិច្ចដែលត្រូវអាស្រ័យច្រើនគ្នានោះឲ្យសម្រេចប្រយោជន៍ទៅបានទេ, ដូចជាអូសឈើបួនសែនសសរជាដើម សូម្បីតាំងចិត្តឲ្យឈើនោះទៅដល់កន្លែងដែលខ្លួនប៉ងប្រាថ្នាជាមួយគ្នានោះ តែគំនិតមិនស្របគ្នាព្រោះមួយឃើញថាធ្វើក្នុងវេលាព្រឹក, មួយឃើញថាធ្វើក្នុងវេលារសៀល, ពុំនោះសោតដូចកិច្ចការប្រជុំធំៗ មានការប្រជុំរបស់រដ្ឋាភិបាលក្នុងនគរនីមួយៗ បើម្នាក់មានសេចក្តីយល់ឃើញផ្សេងមួយ ឃ្លាងគំនិតគ្នាមិនស្របមតិគ្នា ក៏គង់ការប្រជុំនោះមិនបានសម្រេចប្រយោជន៍ ។ ហេតុដូច្នោះការឃើញរួមគ្នាក្នុងការដែលត្រឹមត្រូវដែលសម្រេចប្រយោជន៍, ជាគុណជាតិសំខាន់យ៉ាងទីបំផុតក្នុងករណីយកិច្ចគ្រប់យ៉ាង ។

គណៈសង្គមណា ប្រកបដោយសារាណីយធម៌ ៦ ប្រការនេះ គណៈសង្គមនោះ គួរជាទីស្រឡាញ់ គោរពរាប់អានរបស់មហាជនទាំងពួង នាំឲ្យមានសេចក្តីសង្គ្រោះដល់គ្នានឹងគ្នា មានសេចក្តីព្រមព្រៀងជាមួយគ្នានឹងនាំឲ្យមានសេចក្តីសុខ សេចក្តីចម្រើនអស់កាលជាយូរអង្វែង មិនមានសេចក្តីសាបសូន្យឡើយ ។

សំដែងមកអំពីសារាណីយធម្មកថា ក៏ល្មមសមគួរដល់វេលា សូមសន្មតថាចប់តែប៉ុណ្ណេះ ។

ទុក្ខប្បត្តា ច និទុក្ខា    ភយប្បត្តា ច និព្ភយា
សោកប្បត្តា ច និស្សោកា  ហោន្តុ សព្វេបិ បាណិនោ ។

*សព្វសត្វទាំងឡាយ ដែលដល់ហើយនូវទុក្ខ សូមឲ្យជាសត្វបាត់ទុក្ខទៅ! ដែលដល់ហើយនូវភ័យ សូមឲ្យជាសត្វបាត់ភ័យទៅ! ដែលដល់ហើយនូវសេចក្ដីសោក សូមឲ្យបាត់សេចក្ដីសោកទៅ ! ។*

រតនត្តយតេជេន    កម្ពោជរដ្ឋវាសិនោ
វុឌ្ឍឹ វិរុឡ្ហឹ បប្បោន្តុ   សន្តិភាវញ្ច នាញ្ញថា ។

*ដោយតេជះនៃព្រះរតនត្រ័យ (មានពុទ្ធរតនៈជាដើម) សូមឲ្យប្រជាជនទាំងឡាយ អ្នកកើតនៅក្នុងកម្ពុជរដ្ឋ ដល់នូវការៈលូតលាស់ចម្រើន និងសន្តិភាព កុំបីឃ្លៀងឃ្លាត ក្លាយទៅជាប្រការដទៃឡើយ ។*

ចប់

ស្លាប់ព្រោះជួយជាតិប្រសើរបំផុត

អ្នកណាកើតមក ហើយស្លាប់ទៅវិញ ដោយឥតបានទុកនាមនិងគោត្រ ឲ្យប្រជាជនដឹងផងសោះ អ្នកនោះទុកដូចមិនធ្លាប់មានជីវិតរស់នៅក្នុងលោកឡើយ ។

ឃ. អ.